

# របាយការណ៍ប្រចាំឆ្នាំ ២០២២

ចេញផ្សាយថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣

(អង្គការ ភីខេអេក បានចុះបញ្ជីនៅក្រសួងមហាផ្ទៃក្នុងខែមិថុនាឆ្នាំ២០០៨ និងចុះបញ្ជីជាថ្មី ក្នុងខែមេសា ឆ្នាំ២០២០)

អាសយដ្ឋានៈ ភូមិគោកបេង សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ

011 24 33 44 -077 252 9560

pkh@ponlokkhmer.org

www.ponlokkhmer.org

https://web.facebook.com/pkh.ponlokkhmer/

# សារប្រធានក្រុមប្រឹក្សាភិបាល



ក្នុងនាមក្រុមប្រឹក្សាភិបាលអង្គការ ពន្លកខ្មែរ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង និងឯកភាពទៅលើរបាយការណ៍ប្រចាំឆ្នាំ២០២២ ដែលចាប់ផ្តើមពីខែមករាដល់ចុងបញ្ចប់ខែធ្នូឆ្នាំ២០២២នេះ។ របាយការណ៍នេះ បានបង្ហាញទាំងដំណើរការកម្មវិធីជោគជ័យក្នុងបរិយាកាសប្រតិបត្តិការសមិទ្ធិផលថ្មីៗ និងការពង្រឹងប្រភពផ្តល់ហិរញ្ញប្បទាន។ បើទោះបីជាជួបបញ្ហាកូវីដ ១៩ ក៏អង្គការ ពន្លកខ្មែរ នៅតែអាចសម្របសម្រួលប្រតិបត្តិកម្មវិធីបាន និងរក្សាបាននូវសន្ទុះការងារអភិវឌ្ឍមួយចំនួនគួរអោយជាទីមោទនៈ។ ក្រុមប្រឹក្សាភិបាលសូមចូលរួមអបអរសាទរដល់បុគ្គលិក អង្គការ ពន្លកខ្មែរ ទាំងអស់ដែលបានខិតខំពុះពារ អនុវត្តកម្មវិធី/គម្រោងប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

**ប្រធានក្រុមប្រឹក្សាភិបាល**



**ម៉ុំ វៀម**

# សារនាយកប្រតិបត្តិ



ពន្លកខ្មែរ មានសេចក្តីសោមនស្សរីករាយចែករំលែករបាយការណ៍ប្រចាំឆ្នាំសារពើពន្ធ២០២២ ជាមួយអ្នកពាក់ព័ន្ធទាំងអស់។ ដូចករណីកាលពីឆ្នាំកន្លងទៅដែរ អង្គការ ពន្លកខ្មែរ បានបំពេញបេសកកម្មរបស់ខ្លួនប្រកបដោយសមិទ្ធិផលគួរជាទីមោទនៈ ដូចជាៈ ការប្រើប្រាស់ដីធ្លីប្រកបកសិកម្មរបស់កសិករ និងកិច្ចការពារព្រៃឈើ និងធនធានធម្មជាតិ ការអនុវត្តកសិកម្មប្រតិបត្តិល្អរបស់ជនជាតិដើមភាគតិច ការលើកកំពស់សេដ្ឋកិច្ចគ្រួសារតាមរយៈអាស្រ័យផលដំណាំ ការចិញ្ចឹមសត្វ និងដំណាំ បន្លែបង្កា ជាដើម។

នៅក្នុងរបាយការណ៍ប្រចាំឆ្នាំនេះ បានដាក់បញ្ចូលនូវភាពរីកចំរើនតាមគម្រោងនីមួយៗ ដោយផ្តោតតាមវិស័យ ដូចជាៈ ការប្រើប្រាស់ដីធ្លី ការងារបង្កាត់ពូជស្រូវ ការការពារព្រៃឈើ និងបរិស្ថាន បង្កើតថ្នាលបណ្តុះកូនឈើ សហគមន៍អេកូទេសចរណ៍ ក្រុមស្រ្តីសន្សំប្រាក់ ទុនមូលនិធិសហគមន៍ជាដើម ស្របតាមគោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល និងកម្មវិធីអភិវឌ្ឍន៍សហស្សវត្ស។

ពន្លកខ្មែរ ស្វាគមន៍ម្ចាស់ជំនួយថ្មីៗ និងបច្ចុប្បន្នមានដូចជាៈ Misereor, AJWS,Danida, Diakonia, Danmision, CAFOD, ជាដើម។

ជាថ្មីម្តងទៀត ពន្លកខ្មែរ សូមថ្លែងអំណរគុណចំពោះដៃគូ និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានគាំទ្រក្នុងអំឡុងឆ្នាំកន្លងមក ហើយយើងទន្ទឹងរងចាំធ្វើការរួមគ្នាបន្តទៀត ដើម្បីលើកកំពស់សិទ្ធិពលរដ្ឋ និងប្រព័ន្ធស្បៀងនៅមូលដ្ឋានស្របតាមកម្មវិធីអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា។

**នាយកប្រតិបត្តិ**



**ប៊ឹក សោភ័ណ**

## រៀបចំដោយៈ

លោក **កែវ ស៊ីផុន** បុគ្គលិកត្រួតពិនិត្យ និង វាយតម្លៃ

## ត្រួតពិនិត្យ និងកែសម្រួលភាសាខ្មែរ

លោក **តែម វ៉េន** ប្រធានកម្មវិធី

លោកស្រី **ហេង ចន្ថាទី** ប្រធានរដ្ឋបាល និងហិរញ្ញវត្ថុ

លោក **ប៊ុក សំអុន** ប្រធានគម្រោង

**មាតិកា** **ទំព័រ**

១.ព័ត៌មានអំពីអង្គការពន្លកខ្មែរ ...... ៦
១.១ ទស្សនៈវិស័យ ...... ៦
១.២ គោលដៅ ...... ៦
១.៣ បេសកកម្ម...... ៦
១.៤ គុណតម្លៃ...... ៦
១.៥ តំបន់គោលដៅ ...... ៧
២.របាយការណ៍កម្មវិធីឆ្នាំ២០២២...... ៨
២.១ កម្មវិធីទី១៖ការអភិវឌ្ឍស្ថាប័ន និងការផ្សារភ្ជាប់ទំនាក់ទំនងរបស់សហគមន៍មូលដ្ឋាន ...... ៨
២.២ កម្មវិធីទី២៖ការលើកកម្ពស់ចំណេះដឹងសិទ្ធិសហគមន៍ក្នុងការពិគ្រោះយោបល់កិច្ចការអភិវ.សហគមន៍ ១១
២.៣ កម្មវិធីទី៣៖ការអភិវឌ្ឍសេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពគ្រួសារ សហគមន៍មូលដ្ឋាន ......១៣
២.៤ កម្មវិធីទី៤៖ការអនុវត្តសិទ្ធិធនធានធម្មជាតិ ព្រៃឈើ ដីធ្លីរបស់សហគមន៍មូលដ្ឋាន ......១៦
៣.ការអភិវឌ្ឍស្ថាប័ន និងទំនាក់ទំនង ...... ២១
៣.១ ការបណ្តុះបណ្តាលបុគ្គលិក ...... ២១
៣.២ ការអនុវត្តគោលនយោបាយ ...... ២១
៣.៣ការសិក្សាស្រាវជ្រាវ និងវាយតម្លៃ ...... ២២
៣.៤ កិច្ចសហការជាមួយអង្គការដៃគូអភិវឌ្ឍន៍ និង ស្ថាប័នពាក់ព័ន្ធ...... ២៣
៣.៥ ការផ្សព្វផ្សាយ និងការទំនាក់ទំនង ...... ២៣
៤.របាយការណ៍ហិរញ្ញវត្ថុ ......២៤
៤.១ របាយការណ៍ហិរញ្ញវត្ថុសង្ខេប......២៤
៤.២ បុគ្គលិក......២៥

## ១.ព័ត៌មានអំពីអង្គការពន្លកខ្មែរ

អង្គការពន្លកខ្មែរត្រូវបានគេស្គាល់ថា ជាបណ្តាញចំណេះដឹងជនជាតិដើមភាគតិច ដែលបង្កើតឡើងនាខែកុម្ភៈ ឆ្នាំ ២០០៥ និងបានចុះបញ្ជីលេខ ៨១៨ ស.ជ.ណ ទទួលស្គាល់ដោយក្រសួងមហាផ្ទៃនៅ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៨ ។ អង្គការពន្លកខ្មែរ បានធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធគណៈគ្រប់គ្រង អ.ព.ខ បានចុះបញ្ជីលេខ ១២០០ ស.ជ.ណ នៅក្រសួងមហាផ្ទៃ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ ជាអង្គការមិនរកប្រាក់ចំណេញ និងមិនមាននិន្នាការនយោបាយ។ ចាប់តាំងពីបានបង្កើតឡើងមក អង្គការពន្លកខ្មែរបានធ្វើការផ្តោតលើការងារទាក់ទងនឹង បរិស្ថាន និងសិទ្ធិមនុស្ស ជាពិសេសលើការគ្រប់គ្រងនិងប្រើប្រាស់ធនធានធម្មជាតិ និងបរិស្ថាន របស់ពលរដ្ឋនិងកសិករដែលអាស្រ័យផលព្រៃឈើ រួមទាំងសហគមន៍នៃជនជាតិដើមភាគតិចផងដែរ។

### ១.១ ទស្សនវិស័យ

**អង្គការពន្លកខ្មែរ (អ.ព.ខ)** ចង់ឃើញសង្គមមួយមានអភិបាលកិច្ចល្អ មានការអភិវឌ្ឍ អភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងអនុវត្តនូវសុវត្ថិភាពស្បៀង។

### ១.២ គោលដៅ

អង្គការពន្លកខ្មែរ (អ.ព.ខ) បានកំណត់នូវគោលដៅជាក់លាក់ដូចខាងក្រោម៖

- លើកកម្ពស់សិទ្ធិ និងពង្រឹងការយល់ដឹងរបស់សហគមន៍មូលដ្ឋាន ដែលរស់នៅពឹងអាស្រ័យលើធនធានធម្មជាតិ ព្រៃឈើ ដីធ្លី និងសុវត្ថិភាពស្បៀងអាហារ។
- គាំទ្រសហគមន៍ស្ត្រី ប្រើប្រាស់សិទ្ធិ ភារកិច្ច តួនាទី ក្នុងកិច្ចពិគ្រោះយោបល់លើបញ្ហារួមបញ្ចូលក្នុងកិច្ចការអភិវឌ្ឍ និងដំណោះស្រាយប្រកបដោយប្រសិទ្ធភាព។
- គាំទ្រកសិកម្មធម្មជាតិ(ក្សេត្របរិស្ថាន) ដើម្បីរក្សានិរន្តរភាពបរិស្ថាន ធនធានធម្មជាតិ គុណភាពដី ប្រភពទឹក ពូជដំណាំ និងទទួលទិន្នផល ចំណូលសមរម្យ។
- គាំទ្រការចងក្រង និងភ្ជាប់ទំនាក់ទំនងសហគមន៍មូលដ្ឋាន ជាមួយថ្នាក់ជាតិ និងថ្នាក់តំបន់ ដើម្បីផ្តល់ព័ត៌មានដល់អ្នកតាក់តែងគោលនយោបាយ ឆ្លើយតបតាមសេចក្តីត្រូវការរបស់សហគមន៍។

### ១.៣ បេសកកម្ម

**អង្គការពន្លកខ្មែរ**(អ.ព.ខ) គាំទ្រមនុស្សសកម្មក្នុងការរៀបចំ ចងក្រងសហគមន៍របស់ពួកគេ ការធ្វើទស្សនកិច្ចសិក្សា និងការបង្កើតបណ្តាញសហគមន៍ ដើម្បីពង្រឹងសិទ្ធិអំណាចក្នុងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិ និងលើកកម្ពស់ជីវភាពតាមរយៈការអនុវត្តកសិកម្មក្សេត្របរិស្ថានប្រកបដោយនិរន្តរភាព។

### ១.៤ គុណតម្លៃ

**អង្គការពន្លកខ្មែរ** (អ.ព.ខ) ជឿជាក់លើគុណតម្លៃចំនួនប្រាំចំណុចដូចខាងក្រោម៖

- ធ្វើការងារជាក្រុម និងរៀនសូត្រពីគ្នាទៅវិញទៅមក។
- គោរព អនុវត្តគោលនយោបាយ ភាពជាអ្នកដឹកនាំ និងវប្បធម៌សហគមន៍មូលដ្ឋាន ពិសេសចំណេះដឹង និងរចនាសម្ព័ន្ធចាស់ទុំជនជាតិដើមភាគតិច។
- ការអនុវត្តសិទ្ធិមនុស្ស យុត្តិធម៌ និងគុណភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

- លើកកម្ពស់ និងផ្តល់ឱកាសស្មើគ្នា ដល់ស្ត្រី បុរស កុមារយុវជន ព្រឹទ្ធាចារ្យ ចាស់ទុំ និងជនពិការក្នុងការចូលរួមអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន។
- លើកកម្ពស់គុណភាពវិស័យអប់រំ គាំទ្រការពារថែទាំកុមារ និងការចូលរួមរបស់កុមារទទួលបានយុត្តិធម៌ និងការអភិវឌ្ឍ។

## ១.៥ តំបន់គោលដៅ



## ២.របាយការណ៍កម្មវិធីឆ្នាំ២០២២

### ២.១ កម្មវិធីទី១៖ការអភិវឌ្ឍស្ថាប័ន និងការផ្សារភ្ជាប់ទំនាក់ទំនងរបស់សហគមន៍មូលដ្ឋាន






❖ តាមរយៈគម្រោង“ ការចូលរួមរបស់ពលរដ្ឋដើម្បីយុត្តិធម៌ បរិស្ថានសម្រាប់ទាំងអស់គ្នា” បានរៀបចំវេទិកាក្រុមស្ត្រីប្រតិបត្តិល្អ ដែលមានសមាជិកក្រុមស្ត្រីមកពីតំបន់ជុំវិញព្រៃព្រះរកា គោលបំណងផ្សព្វផ្សាយចំណេះដឹងទាក់ទងនឹងការបន្សាំខ្លួនទៅនឹងបំរែបំរួលអាកាសធាតុ ការអនុវត្តកសិកម្មប្រតិបត្តិល្អបែបប្រពៃណីជនជាតិដើមភាគតិច(កេរ្សត្របរិស្ថាន) និងផ្សព្វផ្សាយអំពីប្រតិទិនរដូវកាលប្រមូលផល អនុផលព្រៃឈើ កិច្ចប្រជុំកម្មវិធីវិនិយោគឃុំ ដោយស្ត្រីលើកយកបញ្ហា តម្រូវការ ក្នុងមូលដ្ឋានរបស់ពួកគាត់ រៀបចំផែនការ តំរូវការដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគឃុំ តាមឃុំគោលដៅនីមួយៗ។



❖ តាមរយៈគម្រោង“លើកកំពស់ជីវភាពសហគមន៍ជនជាតិដើមភាគតិច” បានរៀបចំកិច្ចប្រជុំពង្រឹងចងក្រងបណ្តាញរួមមាន៖ បណ្តាញស៊ីអិនអេ បណ្តាញម្លូព្រៃ បណ្តាញសហគមន៍ព្រៃឈើ បណ្តាញសហគមន៍ជនជាតិដើមភាគតិច បណ្តាញសហគមន៍ព្រៃព្រះរកា បណ្តាញយុវជនបណ្តាញសង្គម ដែលមានសមាជិកចូលរួមមកពី បណ្តាស្រុក គោលបំណងបច្ចុប្បន្នភាពស្ថានភាពជីវភាព សិទ្ធិប្រើប្រាស់ដីធ្លី ព្រៃឈើ ជាពិសេសពង្រឹងតួនាទី ការទទួលខុសត្រូវរបស់គណៈកម្មការតាមបណ្តាញនីមួយៗ។

❖ តាមរយៈគម្រោង “លើកកំពស់ជីវភាពសហគមន៍ជនជាតិដើមភាគតិច” បានរៀបចំកិច្ចប្រជុំចែករំលែកបទពិសោធន៍អនុវត្តន៍ស្រែពិសោធន៍ និងត្រៀមរៀនសូត្របច្ចេកទេសបង្កាត់ពូជស្រូវ រវាងក្រុមកសិករគោលដៅរបស់អង្គការ ពន្លកខ្មែរ នៅខេត្តព្រះវិហារ និងក្រុមកសិករគោលដៅអង្គការ ប៊ីស៊ីវី ភូមិខ្សាច់ល្អិត ឃុំអន្សាចំបក់ ស្រុក

ក្រគរ ខេត្តពោធិ៍សាត់។ ជាលទ្ធផល ក្រុមកសិករបានយល់ដឹងពីដំណាក់កាលនីមួយៗនៃដំណើរការបង្កាត់ពូជស្រូវ ជំនាន់ទី១ ជាពិសេសឧបករណ៍សំខាន់ៗត្រៀមបង្កាត់ពូជនាពេលខាងមុខ។






- តាមរយៈគម្រោង" ការចូលរួមរបស់ពលរដ្ឋដើម្បីយុត្តិធម៌ បរិស្ថានសម្រាប់ទាំងអស់គ្នា" បានរៀបចំវេទិកាពិគ្រោះយោបល់រវាងក្រុមស្ត្រីប្រតិបត្តិល្អ និងអ្នកពឹងអាស្រ័យផលព្រៃឈើ ដើម្បីចែករំលែកចំណេះដឹងប្រពៃណី ប្រតិទិនរដូវកាលប្រមូលបន្លែព្រៃ ការប្រមូលផលជ័រទឹក ការបង្កើនប្រាក់ចំណូលរបស់ក្រុមស្ត្រីបញ្ហាប្រឈមទាក់ទងនឹងសុខភាពស្ត្រី និងកុមារ របបអាហារ និងការត្រៀមខ្លួនចំពោះបញ្ហាបំរែបំរួលអាកាសធាតុជាដើម។







❖ តាមរយៈគម្រោង″ ការចូលរួមរបស់ពលរដ្ឋដើម្បីយុត្តិធម៌ បរិស្ថានសម្រាប់ទាំងអស់គ្នា″ សមាជិកបណ្តាញ សហគមន៍ព្រៃព្រះរកា បានរៀបកិច្ចប្រជុំសមាជប្រចាំឆ្នាំកាលពីអំឡុង ខែធ្នូ ដែលមានសមាជិកបណ្តាញសហគមន៍ព្រៃព្រះរកាមកពីជុំវិញតំបន់ព្រៃព្រះរកាចូលរួមនៅរោងសហគមន៍តំបន់ការពារធម្មជាតិ ព្រៃថ្មគោល ស្ថិតនៅភូមិអូរកក់ ឃុំពោធ៍ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ គោលបំណងដើម្បីសិក្សារៀនសូត្រពីបទពិសោធន៍ល្អ ក្នុងការរៀបចំតំបន់សហគមន៍អេកូទេសចរណ៍ធម្មជាតិ ពិនិត្យលទ្ធភាព និងធនធានដែលនៅក្នុងសហគមន៍ដើម្បីបន្តផែនការអភិវឌ្ឍ និងបច្ចុប្បន្នភាពស្ថានភាពព្រៃព្រះរកានាពេលបច្ចុប្បន្ន។



❖ តាមរយៈគម្រោងភាគីទី៣ របស់បណ្តាញសហគមន៍ព្រៃឈើ សមាជិកគណៈកម្មការបណ្តាញ សហគមន៍ព្រៃឈើតំបន់គោលដៅក្នុងខេត្តព្រះវិហារ បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ឆមាស ដើម្បីចែករំលែកបទពិសោធន៍ប្រតិបត្តិល្អក្នុងកិច្ចការពារព្រៃឈើ និងធនធានធម្មជាតិ និងធ្វើបច្ចុប្បន្នភាពស្ថានភាពព្រៃឈើតាមសហគមន៍របស់ខ្លួន បញ្ហាប្រឈម និងលើកផែនការរួមគ្នា ដើម្បីចូលរួមកិច្ចការពារព្រៃឈើ។

❖ សហគមន៍ព្រៃឈើសង្ឃរុក្ខាវ័នគឺជាសមាជិកបណ្តាញសហគមន៍ព្រៃឈើក្នុងខេត្តឧត្តរមានជ័យដែលបានបង្កើតឡើងឆ្នាំ២០១៤។ ថ្ងៃទី០៥ ខែមេសាឆ្នាំ២០១៨ បានទទួលអនុក្រឹត្យពីរាជរដ្ឋាភិបាលជាតំបន់ការពារជីវចម្រុះព្រៃសហគមន៍សង្ឃរុក្ខាវ័នដែលមានផ្ទៃដី៣០២៥៤ហត។ បច្ចុប្បន្នព្រៃនេះត្រូវបានការពារយ៉ាងសកម្មពីសំណាក់ព្រះសង្ឃ និងទាហានប្រចាំការនៅស្នាក់ការកណ្តាលព្រៃសហគមន៍សង្ឃរុក្ខាវ័ន។




តាមរយៈគម្រោងភាគីទី៣ របស់បណ្ដាញសហគមន៍ព្រៃឈើ អង្គការ ពន្លកខ្មែរ បានគាំទ្រគំនិតផ្ដួចផ្ដើមរបស់អ្នកដឹកនាំសហគមន៍ដូចជាៈ សកម្មភាពល្បាតព្រៃ និងសង្គ្រោះសត្វព្រៃប្រចាំខែ ជីកប្រឡាយកាយព្រំព័ទ្ធជុំវិញបរិវេណព្រៃសហគមន៍ សង់ប៉ុស្តិ៍យាមល្បាត សង់ស្ពាន សង់កញ្ចុះសម្រាប់ភ្ញៀវទេសចរណ៍ រៀបចំផ្លូវភ្លើងការពារភ្លើងឆេះព្រៃ និងកិច្ចប្រជុំពិគ្រោះយោបល់ដើម្បីផលិតផែនការមេអភិវឌ្ឍន៍តំបន់អេកូទេសចរណ៍ធម្មជាតិនាពេលអនាគត។ កិច្ចការការពារព្រៃឈើ សត្វព្រៃ និងធនធានធម្មជាតិនៅតំបន់ព្រៃសហគមន៍ មានការយកចិត្តដាក់ខ្ពស់ពីសំណាក់គណៈកម្មការអ្នកដឹកនាំសហគមន៍ ដោយមានកិច្ចសហការល្អពីសមត្ថកិច្ច និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។

## ២.២ កម្មវិធីទី២ៈការលើកកម្ពស់ចំណេះដឹង សិទ្ធិសហគមន៍ក្នុងការពិគ្រោះយោបល់កិច្ចការអភិវឌ្ឍសហគមន៍

 

តាមរយៈគម្រោង"សហគមន៍ដឹកនាំសកម្មភាពកែលម្អបរិស្ថានឡើងវិញ" អង្គការពន្លកខ្មែរបានរៀបចំក្រុមយុវជនទៅទស្សនៈកិច្ចសិក្សាស្រាវជ្រាវពីមុខម្ហូបប្រពៃណីប្រចាំតំបន់អេកូទេសចរណ៍ នៅសហគមន៍តំបន់ការពារធម្មជាតិជាំពេន ស្ថិតនៅភូមិបង្កើនផល ឃុំរមទម ស្រុករវៀង សហគមន៍ទឹកធ្លាក់ព្រះនិម្មិត ស្ថិតនៅភូមិកំពង់សាមី ឃុំកំពង់ស្រឡៅ ស្រុកឆែប ខេត្តព្រះវិហារ ដែលមានយុជនភូមិគោដៅសរុប៨នាក់ ស្រ្តី៦នាក់៕គោលបំណងដើម្បីបណ្តុះក្រុមយុវជនអោយចេះអង្កេត និងសិក្សាបន្តពីចាស់ទុំ ពីមុខម្ហូបប្រពៃណីប្រចាំតំបន់រៀងៗខ្លួន ដើម្បីបំរើសេវាកម្មភ្ញៀវទេសចរណ៍នាពេលអនាគត។

❖ តាមរយៈគម្រោង" ការចូលរួមរបស់ពលរដ្ឋដើម្បីយុត្តិធម៌បរិស្ថានសម្រាប់ទាំងអស់គ្នា" បានសម្របសម្រួលសមាជិក

សហគមន៍ព្រៃឈើ និងព្រៃព្រះរកាពីខេត្តព្រះវិហារ ចូលរួមព្រឹត្តិការណ៍ដាំកូនឈើនៅព្រៃសហគមន៍សង្ឃរុក្ខាវ័ន ខេត្តឧត្តរមានជ័យ ក្រោមគំនិតផ្តួចផ្តើម និងរៀបចំព្រឹត្តិការណ៍អស្ចារ្យមិនធ្លាប់មានរបស់ព្រះសង្ឃនៅព្រៃសហគម






ន៍រុក្ខាវ័ន ព្រឹត្តិការណ៍នេះដាំកូនឈើ ចំនួន៦៥០០ដើម ក្រោមប្រធានបទ" រួមគ្នាដាំកូនឈើ ដើម្បីជីវិត និងភពផែនដី" កាលពីថ្ងៃទី ១៧ ខែ កក្កដា ២០២២ ដែលមានព្រះសង្ឃពុទ្ធសាសនា គ្រីស្តបរិស័ទ ឥស្លាមបរិស័ទ ជនជាតិដើមភាគតិចកួយ កងកម្លាំងសមត្ថកិច្ច អាជ្ញាធរដែនដី សិស្សានុសិស្ស អង្គការដៃគូ និងអ្នកសារព័ត៌មាន សរុបចំនួន ១៥១៧ អង្គ/នាក់។





- ក្រុមសង្គមស៊ីវិលខេត្តព្រះវិហារ បានសហការរៀបចំព្រឹត្តិការណ៍ទិវាសិទ្ធិជនជាតិដើមភាគតិច ក្រោមប្រធានបទ៖ ប្រព័ន្ធស្បៀង និងសុខមាលភាពជនជាតិដើមភាគតិច គោលបំណងផ្សព្វផ្សាយដល់សាធារណៈជន និងអាជ្ញាធរពាក់ព័ន្ធអំពីប្រវត្តិ របៀបរបបប្រពៃណីនៃការរស់នៅប្រកបរបរចិញ្ចឹមជីវិតរបស់ជនជាតិដើមភាគតិចដែលពឹងអាស្រ័យព្រៃឈើ ជីវៈចម្រុះ និងធនធានធម្មជាតិ និងលើកកំពស់ការចូលរួមក្នុងកិច្ចការងារការពារព្រៃឈើ និងធនធម្មជាតិទាំងអស់គ្នា ជាពិសេសជម្រុញអោយមានការលើកកំពស់ប្រព័ន្ធស្បៀងនៅមូលដ្ឋាន ដោយក្នុងឱកាសនោះ សមាជិកសហគមន៍ជនជាតិដើមភាគតិចបាននាំយកបន្លែ អង្ករ និងអនុផលព្រៃឈើមកតាំងបង្ហាញ និងលក់ផងដែរ។

- ក្រុមសង្គមស៊ីវិលខេត្តព្រះវិហារ បានសហការរៀបចំព្រឹត្តិការណ៍ទិវាសិទ្ធិមនុស្សអន្តរជាតិ១០ធ្នូ នៅសួនផ្លូវភ្លោះ វិមានឯករាជ្យ ក្រុងព្រះវិហារ ខេត្តព្រះវិហារ ដែលមានអ្នកចូលរួមជាជនជាតិដើមភាគតិច និងមិនមែនជាជនជាតិដើមភាគតិច អាជីវករ សមត្ថកិច្ច និងអាជ្ញារមូលដ្ឋានសុរប ៨១៧អង្គ/នាក់(ស្ត្រី៣៧៧នាក់ យុវជន១៧៩នាក់ និងជនជាតិដើមភាគតិច២៨៤នាក់)។ គោលបំណងដើម្បីផ្សព្វផ្សាយអំពីសិទ្ធិមនុស្សជាមូលដ្ឋាន ក្នុងការចូលរួមការងារអភិវឌ្ឍប្រទេសជាតិ។



## ២.៣ កម្មវិធីទី៣៖ការអភិវឌ្ឍសេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពគ្រួសារ សហគមន៍មូលដ្ឋាន

- តាមរយៈគម្រោងគាំទ្រជីវភាពសហគមន៍ជនជាតិដើមភាគតិច អង្គការ ពន្លកខ្មែរ បានគាំទ្រទុនមូលនិធិសហគមន៍ដល់គ្រួសារដែលក្រីក្រខ្វះមធ្យោបាយបង្កបង្កើនផលដំណាំ តាមរយៈការកំណត់ជាក់លាក់ពីសំណាក់សមាជិកក្រុមស៊ីអិនអេ ប្រចាំស្រុកទាំងបី ស្រុកឆែប ស្រុកត្បែងមានជ័យ និងស្រុកជ័យសែន បានគាំទ្រធនធានថវិកាអំឡុងកូវីដ ដែលកសិករខ្វះខាតមធ្យោបាយអាស្រ័យផលលើដីធ្លី ស្រែចម្ការរបស់ខ្លួន ជាលទ្ធផលបានគ្រាំកសិករចំនួន៧២គ្រួសារ មកពី១១ភូមិ ៧ឃុំ ក្នុងចំណោមស្រុកទាំងបី ប្រើប្រាស់ថវិកាសរុប២៤,៦២៥,៥០០០.០០(ម្ភៃបួនលានប្រាំមួយរយម្ភៃប្រាំពាន់ ប្រាំពាន់ រៀល ។




គណៈកម្មការប្រាក់មូលនិធិសហគមន៍ផ្តល់ប្រាក់កម្ចីមូលនិធិដល់គ្រួសារកសិករក្រីក្រ ឃុំស្អាង និងឃុំសង្កែពីរ




- តាមរយៈគម្រោង៉ ការចូលរួមរបស់ពលរដ្ឋដើម្បីយុត្តិធម៌បរិស្ថានសម្រាប់ទាំងអស់គ្នា៉ អង្គការ ពន្លកខ្មែរបានចែករំលែកបច្ចេកទេសការគ្រប់គ្រងភាពជាអ្នកដឹកនាំ និងគ្រប់គ្រងហិរញ្ញវត្ថុដល់ក្រុមស្ត្រីជារៀងរាល់ខែ បុគ្គលិកគម្រោងបានចុះ ភូមិគោលដៅក្រុមសន្សំទាំង១០ភូមិរួមមាន៖ ភូមិប្រមេរ ភូមិស្រែព្រាង ឃុំប្រមេរ ស្រុកត្បែងមានជ័យ ភូមិប្រើសក្អក ឃុំម្លូព្រៃពីរ ស្រុកឆែប ភូមិអូរកក់ ឃុំពោធិ៍ ស្រុកត្បែងមានជ័យ ភូមិរបុញ ឃុំមរកត ស្រុកជាំក្សាន្ត ភូមិក្រាំងដូង អន្លង់ស្វាយ ឃុំព្រះឃ្លាំង ស្រុកត្បែងមានជ័យ ភូមិដូនម៉ា ភូមិព្រាល ឃុំរក្សា ស្រុករវៀង ភូមិកក់ពោន ឃុំរំដោះ ស្រុករវៀង ដើម្បីជួយពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ ការបែងចែកភាគលាភ ជាពិសេសក្រុមស្ត្រីតែងមានការផ្សព្វផ្សាយអំពី គោលការណ៍ក្រុមសន្សំប្រាក់មួយចំនួនដូចជាៈការប្រើប្រាស់ប្រាក់កម្ចីក្រុមសន្សំ ការបង្កើតមុខរបរខ្នាតតូច ការដាំបន្លែ ការចិញ្ចឹមសត្វដើម្បីគាំទ្រសេដ្ឋកិច្ចគ្រួសារប្រចាំថ្ងៃ ជាពិសេសការមិនប្រើប្រាស់ជីគីមីកសិកម្ម ប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត ថ្នាំបាញ់ស្មៅ។ល។

ជាលទ្ធផលសមាជិកក្រុមស្ត្រីមានការយល់ដឹងពីការគ្រប់គ្រងចំណូល និងចំណាយ បង្កើតខ្ទង់ថវិកាសន្សំប្រចាំខែជាទៀងទាត់ ពិភាក្សាផ្តល់យោបល់គ្នាទៅវិញទៅមក ចែករំលែកចំណេះដឹងពាក់ព័ន្ធនឹងសុខភាពស្ត្រីកុមារ ការផ្គត់ផ្គង់ស្បៀងអាហារប្រចាំថ្ងៃដល់ក្រុមគ្រួសារ ជាពិសេសកុមារ និងការជម្រុញ ឧបត្ថម្ភការសិក្សារៀនសូត្ររបស់កុមារ ការបង្កើតប្រាក់ចំណូលតាមរយៈការដាំបន្លែ ចិញ្ចឹមសត្វ លក់ចាប់ហួយជាដើម។

❖ តាមរយៈគម្រោង″ ការចូលរួមរបស់ពលរដ្ឋដើម្បីយុត្តិធម៌បរិស្ថានសម្រាប់ទាំងអស់គ្នា″ ដោយសហការជាមួយមន្ទីរពាណិជ្ជកម្មខេត្តព្រះវិហារ អង្គការ ពន្លកខ្មែរ បានសម្របសម្រួលអោយក្រុមស្ត្រីអនុវត្តន៍កសិកម្មប្រតិបត្តិល្អប្រពៃណីជនជាតិដើមភាគតិចទាំង១០ភូមិ ក្រុមគោលដៅ នាំយកផលិតផលកសិកម្ម បន្លែ សត្វមាន់ ទា និងអនុផលព្រៃឈើលក់ក្នុងកម្មវិធីផ្សារចុងសប្តាហ៍ក្នុងទីរួមខេត្តព្រះវិហារជារៀងរាល់ខែ និងក្រុងសៀមរាបបានចំនួន ២លើក និងលក់នៅតាមភូមិផងដែរ។







សមាជិកបណ្តាញទៅទស្សនៈកិច្ចសិក្សាព្រៃសហគមន៍សង្ឃរុក្ខាវ័ន អំឡុងខែកញ្ញា ឆ្នាំ២០២២

- តាមរយៈគម្រោង ″ពង្រឹងណ្តាញសហគមន៍មូលដ្ឋាន″ អង្គការ ពន្លកខ្មែរ បានសម្របសម្រួលសមាជិកបណ្តាញសហគមន៍ព្រៃឈើ និងព្រៃព្រះរកាទៅធ្វើទស្សនៈកិច្ចសិក្សានៅព្រៃសហគមន៍សង្ឃរុក្ខាវ័ន ក្នុងខេត្តឧត្តរមានជ័យ គោលបំណងត្រួតពិនិត្យស្ថានភាពព្រៃ សិក្សាភូមិសាស្រ្តបង្កើតតំបន់អេកូទេសចរណ៍ និងរៀនសូត្រពីការអនុវត្តប្រតិបត្តិល្អនៃកិច្ចការពារព្រៃឈើ ធនធានធម្មជាតិ សត្វព្រៃ នៅក្នុងតំបន់ព្រៃសហគមន៍សង្ឃ របស់គណៈកម្មការសហគមន៍សង្ឃ និងកិច្ចសហការរបស់សមត្ថកិច្ច មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។

## ២.៤ កម្មវិធីទី៤៖ការអនុវត្តសិទ្ធិធនធានធម្មជាតិ ព្រៃឈើ ដីធ្លីរបស់សហគមន៍មូលដ្ឋាន

- តាមរយៈគម្រោង″ពង្រឹងណ្តាញសហគមន៍មូលដ្ឋាន″ បានរៀបចំវេទិកាបណ្តាញកសិករ និងអ្នកពឹងអាស្រ័យផលព្រៃឈើ ទៅធ្វើទស្សនៈកិច្ចសិក្សានៅព្រៃសហគមន៍សង្ឃរុក្ខាវ័ន ខេត្តឧត្តរមានជ័យ





នៅស្នាក់ការកណ្តាលសហគមន៍សង្ឃរុក្ខាវ័ន និង ធ្វើដំណើរទស្សនកិចច្ចសិក្សាទៅតំបន់ទឹកលិច ក្បែរវត្តភ្នំអាតោ ដោយធ្វើដំណើរតាមគោយន្ត និងម៉ាស៊ីនកាណូតកាត់ព្រៃសហគមន៍ ដែលមានការចូលរួមពីសមាជិកបណ្តាញគោលដៅដូចជាៈបណ្តាញម្លូព្រៃ បណ្តាញសហគមន៍ព្រៃឈើព្រះវិហារ បណ្តាញជនជាតិដើមភាគតិច បណ្តាញសកម្មភាពដើម្បីសហគមន៍ បណ្តាញសហគមន៍ព្រៃព្រះរកា។ គោលបំណងសិក្សាភូមិសាស្រ្តបង្កើតតំបន់អេកូទេសចរណ៍ និងរៀនសូត្រពីការអនុវត្តប្រតិបត្តិល្អនៃកិច្ចការពារព្រៃឈើ ធនធានធម្មជាតិ សត្វព្រៃ នៅ

ក្នុងតំបន់ព្រៃសហគមន៍សង្ឃ របស់គណៈកម្មការសហគមន៍ដឹកនាមដោយព្រះសង្ឃ និងកិច្ចសហការរបស់សមត្ថកិច្ច មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។

- តាមរយៈគម្រោង"លើកកំពស់ជីវភាពសហគមន៍ជនជាតិដើមភាគតិច" បានរៀបចំទស្សនៈកិច្ចសិក្សា ដឹកនាំក្រុមស្ត្រីកសិករភូមិគោលដៅអនុវត្តន៍ស្រែពិសោធន៍ពូជស្រូវ ទៅទស្សនកិច្ចសិក្សារៀនសូត្រពីសមាជិកសហគមន៍





ក្រុមស្ត្រីកសិករគោលដៅរបស់អង្គការ ប៊ីស៊ីវី នៅភូមិខ្សាច់ល្អិត ឃុំអន្សាចំបក់ ស្រុកក្រគរ ខេត្តពោធិ៍សាត់។ ជាលទ្ធផលក្រុមកសិករបានចែករំលែកពីការអនុវត្តសិទ្ធិប្រើប្រាស់ដីធ្លី បច្ចេកទេសចិញ្ចឹមសត្វ បច្ចេកទេសអនុវត្តន៍ស្រែពិសោធន៍ និងបង្កាត់ពូជស្រូវ ដោយសារក្រុមកសិករខេត្តព្រះវិហារទើបតែអនុវត្តន៍ស្រែពិសោធន៍ឆ្នាំទី១ និងបន្តអនុវត្តន៍បច្ចេកទេសបង្កាត់ពូជស្រូវនៅឆ្នាំ២០២២នេះ ជំនាន់ទី១។

- តាមរយៈគម្រោង"លើកកំពស់ជីវភាពសហគមន៍ជនជាតិដើមភាគតិច" អង្គការ ពន្លកខ្មែរ បានគាំទ្រគំនិតផ្តួចផ្តើមរបស់កសិករក្នុងការអភិរក្ស និងលើកកំពស់ពូជស្រូវក្នុងស្រុក/មូលដ្ឋាន ដោយអនុវត្តន៍ស្រែពិសោធន៍តាំងពីឆ្នាំ២០០២១ ដែលមាន៥ភូមិ ក្នុងឃុំតស៊ូ ១ភូមិក្នុងឃុំស្អាង ស្រុកជ័យសែន ៣ភូមិ ក្នុងឃុំសង្កែពីរ ស្រុកឆែប និង ១ភូមិ ក្នុងឃុំប្រមេរ ស្រុកត្បែងមានជ័យ សរុបចំនួន ១៦ គ្រួសារកសិករ។ កសិករតំបន់គោលដៅ រីករាយនិងពេញចិត្តចំពោះការងារនេះ ដោយសារជាបច្ចេកទេសថ្មី សម្រាប់ការសិក្សាស្រាវជ្រាវ និងថែរក្សាអភិរក្សពូជដោយខ្លួនឯង។




- តាមរយៈគម្រោង"លើកកំពស់ជីវភាពសហគមន៍ជនជាតិដើមភាគតិច" អង្គការ ពន្លកខ្មែរ បានគាំទ្រគំនិតផ្តួចផ្តើមរបស់កសិករក្នុងការអភិរក្ស និងលើកកំពស់ពូជស្រូវក្នុងស្រុក/មូលដ្ឋាន ដោយអនុវត្តន៍បច្ចេកទេសបង្កាត់ពូជស្រូវ ជំនាន់ទី១ ឆ្នាំ២០២២ ជាលទ្ធផលទទួលបានលទ្ធផលពីការបង្កាត់ជំនាន់ទី១ ល្អបង្គួរ ដោយសារបទពិសោធន៍ថ្មី មានបញ្ហាប្រឈមមួយចំនួនដូចជាៈ អាកាសធាតុ ការថែទាំមិនបានល្អ កត្តាគ្រាប់ពូជជាដើម។ តែទោះជាយ៉ាងណា កសិករបានតាំងចិត្តនឹងបន្តអនុវត្តន៍ជំនាន់ទី២អោយបានលទ្ធផលល្អជាងនេះ។
- តាមរយៈគម្រោង"ការចូលរួមរបស់ពលរដ្ឋដើម្បីយុត្តិធម៌បរិស្ថានសម្រាប់ទាំងអស់គ្នា" អង្គការ ពន្លកខ្មែរ បានសម្របសម្រួលអោយមានកម្មវិធីចែករំលែកចំណេះដឹងប្រពៃណីប្រតិបត្តិល្អពីសំណាក់ចាស់ទុំ អ្នកដឹកនាំបែបប្រពៃណី ទៅដល់យុវជននៅជុំវិញតំបន់ព្រៃព្រះរកា ទាំងជនជាតិដើមភាគតិច និងមិនមែនជាជនជាតិដើមភាគតិច នូវការដកហូតអនុផលព្រៃឈើបែបប្រពៃណី ជាពិសេសការប្រមូលផលជ័រទឹកពីដើមច្បោះដែលធានានូវនិរន្តរ

ភាពព្រៃឈើ ជីវចម្រុះនិងធនធានធម្មជាតិសម្រាប់ក្មេងជំនាន់ក្រោយ ជាពិសេសជួយទៅដល់ការទប់ទល់នឹងបញ្ហាបំរែបំរួលអាកាសធាតុ។





- តាមរយៈគម្រោង "សហគមន៍ដឹកនាំសកម្មភាពដើម្បីកែលម្អបរិស្ថានឡើងវិញ" ពន្លកខ្មែរបានគាំទ្រគំនិតផ្ដួចផ្ដើម




របស់អ្នកដឹកនាំក្នុងភូមិគោលដៅ សហគមន៍ជនជាតិដើមភាគតិចកួយឃុំប្រមេរ ស្ថិតនៅឃុំប្រមេរ ស្រុកត្បែងមានជ័យ សហគមន៍តំបន់ការពារធម្មជាតិជាំពេន ស្ថិតនៅភូមិបង្កើនផល ឃុំរមទម ស្រុករវៀង សហគមន៍អេកូទេសចរណ៍ទឹកធ្លាក់ព្រះនិម្មិត ស្ថិតនៅឃុំកំពង់ស្រឡៅ ស្រុកឆែប និងសហគមន៍តំបន់ការពារធម្មជាតិ ព្រៃថ្ម

គោល ស្ថិតនៅភូមិអូរកក់ ឃុំពោធិ៍ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ។ គំនិតផ្តួចផ្តើមទាំងអស់នោះត្រូវបានដាក់បញ្ចូលក្នុងផែនការមេ  អភិវឌ្ឍន៍តំបន់ព្រៃសហគមន៍អោយក្លាយជាតំបន់អេកូទេសចរណ៍រួមមានដូចជា៖  បង្កើតក្រុមរបាំយុវជនជនជាតិដើមភាគតិច ក្រុមចុងភៅមុខម្ហូបព្រៃណី ផ្ទះស្នាក់សម្រាប់ភ្ញៀវ ក្រុមមគ្គុទេសនាំភ្ញៀវ ប៉ុស្ដិ៍ល្បាត  សង់ស្ពាន ដាំដំណាំ ចិញ្ចឹមសត្វក្នុងព្រៃសហគមន៍ សង់ក្រោលគោ បង្កើតក្រុមជាងឈើ សង់រោងជាងផលិតរទេះដឹងភ្ញៀវ សាងសង់មជ្ឈមណ្ឌលវប្បធម៌ ជីកស្រះ  កន្លែងបោះជំរុំ/ បោះតង់។ល។

❖ តាមរយៈគម្រោង"ការចូលរួមរបស់ពលរដ្ឋដើម្បីយុត្តិធម៌បរិស្ថានសម្រាប់ទាំងអស់គ្នា" អង្គការ ពន្លកខ្មែរ បានគាំទ្រគំនិតផ្តួចផ្តើមរបស់សមាជិកបណ្ដាញសហគមន៍ព្រៃព្រះរកា និង  អ្នកពឹងអាស្រ័យផលព្រៃឈើរៀបចំថ្នាលបណ្តុះកូនឈើរួមមាន៖




- ថ្នាល់បណ្តុះទី១៖ ទំហំទទឹង៦.៥ម៉ែត្រ និងបណ្តោយ១២ម៉ែត្រ បណ្តុះប្រភេទពូជឈើ បេង ធ្នង់ ស្វាយ និងដើមរាជ ស្ថិតនៅបរិវេណវត្តពោធិ៍កែវមានជ័យ ភូមិពោធិ៍ ឃុំពោធិ៍ ស្រុកត្បែងមានជ័យខេត្តព្រះវិហារ។
- ថ្នាលបណ្តុះទី២៖ ទំហំទទឹង៤ម៉ែត្រ និងបណ្តោយ៦ម៉ែត្រ បណ្តុះប្រភេទពូជឈើ បេង នាងនួន ស្ថិតនៅភូមិម្លូព្រៃ ឃុំម្លូព្រៃមួយ ស្រុកឆែប ខេត្តព្រះវិហារ ។

- ថ្នាលបណ្តុះទី៣៖ ទំហំទទឹង៧ម៉ែត្រ និងបណ្តោយ៩ម៉ែត្រ បណ្តុះប្រភេទពូជឈើកូនចន្ទី ដូង ខ្នុរ ទ្រាំង ស្រទៀវ បេង ធ្នង់ ស្ថិតនៅភូមិសង្កែ ឃុំសង្កែមួយ ស្រុកឆែប ខេត្តព្រះវិហារ ។
- ថ្នាលបណ្តុះទី៤៖ ទំហំទទឹង៤ម៉ែត្រ និងបណ្តោយ៦ម៉ែត្របណ្តុះប្រភេទពូជឈើហូបផ្លែស្ថិតនៅភូមិសំរោង ឃុំតសូ ស្រុកជ័យសែន ខេត្តព្រះវិហារ។

## ៣.ការអភិវឌ្ឍស្ថាប័ន និងទំនាក់ទំនង

### ៣.១ ការបណ្តុះបណ្តាលបុគ្គលិក

ឆ្នាំ២០២២ ជាឆ្នាំយុទ្ធសាស្ត្រក្នុងការពង្រឹងស្ថាប័ន បុគ្គលិកអង្គការភីខេអេក បានចូលរួមវគ្គបណ្តុះបណ្តាល ការប្រើប្រាស់ឧបករណ៍ដ្រូន របៀបប្រើប្រាស់កម្មវិធីប្រមូលទិន្នន័យ សិក្ខាសាលា យុទ្ធសាស្ត្រកៀងគរថវិកា វិធីសាស្ត្រសំអាតទិន្នន័យ ការប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យតាមដាននិងវាយតម្លៃ កិច្ចប្រជុំផ្សព្វផ្សាយគោលនយោបាយផ្សេងៗទាក់ទងនឹង ច្បាប់សវនកម្មគណនេយ្យ និងពន្ធដារ ច្បាប់ស្តីពីការងារ ច្បាប់អង្គការសមាគម ការប្រើប្រាស់របបសន្តិសុខសង្គម ។ល។




### ៣.២ ការអនុវត្តគោលនយោបាយ

អង្គការ ពន្លកខ្មែរ បាននឹងកំពុងអនុវត្តន៍គោលនយោបាយសម្រាប់ស្ថាប័នយ៉ាងខ្ជាប់ខ្ជួនរួមមាន៖ គោលនយោបាយរដ្ឋបាល និងហិរញ្ញវត្ថុ គោលនយោយបណ្តឹងសារទុក គោលនយោបាយបុគ្គលិក គោលនយោបាយការពារកុមារ និងស្ត្រី គោលនយោបាយសុវត្ថិភាពបុគ្គលិក គោលនយោបាយសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាន អនុវត្តន៍ច្បាប់សវនកម្ម និងគណនេយ្យ ច្បាប់ស្តីពន្ធដារ ច្បាប់ស្តីពីការងារ។ល។

## ៣.៣ការសិក្សាស្រាវជ្រាវ និងវាយតម្លៃ

❖ **កិច្ចប្រជុំជាមួយក្រុមប្រឹក្សាភិបាល**



គណៈគ្រប់គ្រងនៃអង្គការ ពន្លកខ្មែរបានរៀបចំកិច្ចប្រជុំជាមួយសមាជិកក្រុមប្រឹក្សាភិបាលប្រចាំត្រីមាសជាទៀងទាត់ដើម្បីរាយការណ៍វឌ្ឍនភាពកម្មវិធី ស្ថានភាពមូលនិធិបញ្ហាប្រឈមនិងកិច្ចការអភិវឌ្ឍស្ថាប័ន ដើម្បនិរន្តរភាពការងារអភិវឌ្ឍ សហគមន៍។

❖ **រៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងកម្មវិធីប្រចាំឆ្នាំ**



អំឡុងពេលកិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំ ដោយមានការចូលរួមពីបុគ្គលិកគ្រប់ផ្នែក សមាជិកក្រុមប្រឹក្សាភិបាល សមាជិកគណៈគ្រប់គ្រងនៃអង្គការពន្លកខ្មែរបានធ្វើបច្ចុប្បន្នភាពដំណើរអនុវត្តន៍គម្រោង លទ្ធផលប្រចាំឆ្នាំ បញ្ហាប្រឈម របាយការណ៍ហិរញ្ញវត្ថុ និង ផែនការសកម្មភាព និងផែនការថវិកាសម្រាប់ឆ្នាំ ២០២៣។

❖ **រៀបចំសិក្សាវាយតម្លៃពាក់កណ្តាលយុទ្ធសាស្រ្ត**



ក្នុងឆ្នាំ២០២២ នេះ ជាឆ្នាំពាក់កណ្តាលយុទ្ធសាស្រ្ត ២០២០-២០២៤ ក្រុមគណៈគ្រប់គ្រងនៃអង្គការពន្លកខ្មែរ បានរៀបចំកិច្ចការវាយតម្លៃ ដោយមានការចូលរួមពីក្រុមគោលដៅ អ្នកទទួលផលជាអ្នកដឹកនាំសហគមន៍តាមរយៈបង្កើតទម្រង់បញ្ជីសំណួរដើម្បីឆ្លើយតបទៅនឹងក្របខ័ណ្ឌលទ្ធផល ផ្នែកគោលដៅ ភាពទាក់ទងគ្នា ប្រសិទ្ធភាព ប្រសិទ្ធផល និរន្តរភាព និងការផ្តល់មតិត្រលប់ពីវិធីសាស្រ្តអនុវត្តន៍កម្មវិធី និងគម្រោងនីមួយៗ ក្នុងការចូលរួមការងារអភិវឌ្ឍជាមួយរាជរដ្ឋាភិបាល។

## ៣.៤ កិច្ចសហការជាមួយអង្គការដៃគូអភិវឌ្ឍន៍ និង ស្ថាប័នពាក់ព័ន្ធ

អង្គការ ពន្លកខ្មែរ ផ្ដើការផ្ដោតលើកិច្ចការអភិវឌ្ឍសហគមន៍មូលដ្ឋាន លើកកំពស់ការគោរពសិទ្ធិមនុស្ស សិទ្ធិគ្រប់គ្រង និងប្រើប្រាស់ព្រៃឈើ ធនធានធម្មជាតិ បរិស្ថាន ដោយមានកិច្ចសហការជាមួយក្រុមសង្គមស៊ីវិលក្នុងខេត្តព្រះវិហារ រួមមានអង្គការ ឌីភីអេ អង្គការ អនុផលព្រៃឈើ អង្គការ ភីអិនខេអេស សមាគមអាដហុក អង្គការអូភីខេស៊ី អង្គការសង្គមស៊ីវិលថ្នាក់ជាតិ និងថ្នាក់តំបន់។ ជាពិសេស អង្គការពន្លកខ្មែរ បានធ្វើការសហការ និងទំនាក់ទំនងយ៉ាងជិតស្និទជាមួយអាជ្ញាធរ ថ្នាក់ខេត្ត មន្ទីរ ក្រុង ស្រុក និងឃុំសង្កាត់។



## ៣.៥ ការផ្សព្វផ្សាយ និងការទំនាក់ទំនង

អង្គការ ពន្លកខ្មែរ ប្រើប្រាស់ប្រព័ន្ធទំនាក់ទំនង និងផ្សព្វផ្សាយផ្លូវការចំនួនពីរគឺ៖ ហ្វេសប៊ុកផេក និង វេបសាយ។ តំណភ្ជាប់ផេកខាងក្រោម

https://web.facebook.com/pkh.ponlokkhmer



វេបសាយផ្លូវការរបស់ស្ថាប័នត្រូវបានអភិវឌ្ឍន៍ឡើងជាពីរភាសា៖ ភាសាខ្មែរ និងភាសាអង់គ្លេស។ ខាងក្រោមជា





តំណភ្ជាប់៖https://ponlokkhmer.org/

ក្រៅពីប្រព័ន្ធផ្សព្វផ្សាយផ្លូវការទាំងពីរ អង្គការ ពន្លកខ្មែរក៏បានចងក្រង ឯកសារមួយចំនួនដូចជា៖ កម្រងអត្ថបទព័ត៌មានករណីដីធ្លី ព្រៃឈើ បរិស្ថាន និងធនធានធម្មជាតិប្រចាំឆ្នាំ ដកស្រង់ចេញពីប្រព័ន្ធបណ្ដាញសង្គម ឯកសារជំនួយសម្រាប់កសិករស្ដីពីការបង្កាត់ពូជស្រូវ និងស្រែពិសោធន៍។

## ៤.របាយការណ៍ហិរញ្ញវត្ថុ

### ៤.១ របាយការណ៍ហិរញ្ញវត្ថុសង្ខេប




| | |
|---|---|
| ចំណូលសរុប | ៣២០,៩២៣.៥៥ |
| ចំណូលផ្សេងៗ | ៦៧២.៦១ |
| ចំណាយសរុប | ២១៦,៩៤១.៥០ |
| សមតុល្យយោងទៅឆ្នាំបន្ទាប់ | ១០៤,៦៥៤.៦៦ |

ក្នុងឆ្នាំ២០២២ អង្គការ ពន្លកខ្មែរ ទទួលបានថវិកាពីប្រភព៖ ម្ចាស់មូលនិធិសរុបចំនួនជាង ៣២០ ពាន់ដុល្លារអាមេរិក ចំណូលពីផ្នែកផ្សេងៗប្រមាណ ៦៧២ ដុល្លារអាមេរិក ចំណាយសរុបប្រមាណជាង ២១៦ពាន់ដុល្លារអាមេរិក សមតុល្យប្រមាណ១០៤ពាន់ដុល្លារអាមេរិក បំរុងសម្រាប់ចំណាយឆ្នាំ ២០២៣។

## ៤.២ បុគ្គលិក

ក្នុងឆ្នាំ២០២២ អង្គការ ពន្លកខ្មែរ មានបុគ្គលិកជាគណៈគ្រប់គ្រង នាយកប្រតិបត្តិ ប្រធានកម្មវិធី ប្រធានរដ្ឋបាលនិងហិរញ្ញវត្ថុ បុគ្គលិកគណនេយ្យករ ប្រធានគម្រោង បុគ្គលិកទំនាក់ទំនង បុគ្គលិកតាមដានត្រួតពិនិត្យ និងវាយតម្លៃ បុគ្គលិកសម្របសម្រួលផ្នែកអភិវឌ្ឍន៍សហគមន៍ និងជំនួយការការិយាល័យ សរុបចំនួន ១៣ រូប ស្រ្តី ០៥រូប។

